ក្រសួងអប់រំ យុវជន និង កីឡា

# ២ ផ្ទាំងផ្ដុំរូបភាព

## បញ្ឈប់ពលកម្មកុមារ

### ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

## វត្ថុបំណង

បង្កើតគំនូរដោយផ្គុំរូបតូចៗពីរផ្ទាំង មួយផ្ទាំងស្តីពីទីផ្សារបុរាណហើយមួយទៀតស្តីពីពលកម្មកុមារ ។





## លទ្ធផលរំពឹងទុក

ជំរុញលើកទឹកចិត្តសិស្សអោយបង្កើនការសំដែងសិល្បៈ និងទស្សនីយភាពហើយបង្ហាញឱ្យឃើញថាប្រព័ន្ធផ្សព្វផ្សាយ បានចេញផ្សាយអត្ថបទខ្លីៗស្តីអំពីបញ្ហាដ៏ធំមួយ ដូចជា ពលកម្មកុមារជាដើម ។

## ការកំណត់ពេលវេលា

បង្រៀន២ពេលជាប់គ្នា ឬ ដាច់ពីគ្នា ។



## ហេតុផល

គោលបំណងសំខាន់នៃលំហាត់ធ្វើគំនូរផ្ទាំងរូបភាពតូចៗ គឺដើម្បីជួយមនុស្សវ័យក្មេងទាំងឡាយ ឱ្យយល់អំពីចរិកអាចិកំបាំងរបស់ពលកម្មកុមារ និងបង្ហាញឱ្យឃើញថាវា ពិបាកប៉ុណ្ណាក្នុងការបង្កើតរូបភាពដែលពណ៌នាអំពីពលកម្មកុមារតាមរយៈសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃធម្មតា ។

ក្នុងសង្គមសព្វថ្ងៃនេះ រូបភាពទាំងអស់បានបង្ហាញបញ្ហាទាំងអស់នេះ នៅពេលដែលបញ្ហានេះ កើតមានដល់មនុស្សវ័យក្មេងទាំងឡាយ ។ ព័តិមានផ្សព្វផ្សាយតាមរយៈការសរសេរដែលមានបំណង ឆ្ពោះទៅរកមនុស្សពេញវ័យទាំងអស់ មានសៀវភៅរឿង សៀវភៅរូបភាពស្ទើរតែទាំងអស់ ដូចជារូបថតមួយចំនួនធំ រូបភាព,រូបគំនូរជីវចលហើយនឹងក្រាហ្វិក ។ ក៏ប៉ុន្តែមានមួយចំនួនតូចត្រូវបង្ហាញតាម វិធីប្រើពាក្យសំដី ។ ទូរទស្សន៍ , កុន, វីដេអូល្បែងកុំព្យូទ័រ និងរបស់របរគ្រប់ប្រភេទនៃម៉ាស៊ីនអេឡិចត្រូនិច

### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

សៀវភៅផ្គុំរូបភាពនេះអាចជាមេរៀនដំបូងបំផុតមួយដែលត្រូវប្រតិបត្តិក្រុមមនុស្សវ័យ ក្មេងទាំងអស់ ដែលអ្នកកំពុងធ្វើការជាមួយនោះត្រូវតែដឹងបន្តិចបន្តួចអំពីពលកម្មកុមារក្នុងគោលបំណងចូលរួមក្នុងលំហាត់នេះការធ្វើឱ្យកុមារគិតនិងនិយាយអំពីបញ្ហារបស់គេនិងរំលេចបញ្ហានោះតាមរបៀបធម្មតាកំប្លុកកំប្លែង និងតាមរបៀបច្នៃប្រឌិតនៅក្នុងកម្មវិធីទាំងមូលនេះគឺជាការល្អប្រសើរ ។

តូចៗដែលទាក់ទាញបំរុងប្រយ័ត្ន មនុស្សវ័យក្មេងទាំងឡាយ ហើយនិងបញ្ជូនទៅឱ្យពួកគេនូវប្រដាប់ដែលផ្លាស់ប្តូររូបភាពបានឆាប់រហ័ស ។រូបភាពទាំងនោះមិនបង្ហាញការសន្ទនាច្រើនទេ ក៏ប៉ុន្តែវាមានសកម្មភាពរាប់មិនអស់ ។ សង្គមបានបង្កើតមនុស្សជំនាន់ក្រោយចេញមកពីគំនិតថា " ខ្ញុំចង់បានវាទាំងអស់, ហើយខ្ញុំចង់បាន វាឥឡូវនេះយ៉ាងឆាប់យ៉ាងឆើត យ៉ាងឆ្លាតវៃ " ។

ផ្ទុយមកវិញ រូបភាពស្តីពីពលកម្មកុមារមានតិចតួច ។ នេះគឺបាតុភូតដែលពិភពលោកមើលមិនឃើញសូម្បីតែនៅក្នុងប្រទេសជាច្រើនដែលបញ្ហាពលកម្មកុមារកើតមានក៏ដោយ ។



មូលហេតុនៃការមើលមិនឃើញបណ្តាលមកពីការខ្វះខាតនៃការយល់ដឹងមួយផ្នែក និងមួយផ្នែកទៀតបណ្តាលមកពីមិនព្រមស្តាប់សេចក្តីពិត ។"សួរថាតើក្មេងទាំងអស់ត្រូវតែធ្វើការឬ ? តាមការពិតអត់ទេ ។ ក្មេងទាំងនោះនៅ ឯណា? កុំនិយាយអំពីរឿងឥតបានការ ។"នេះជាចង្ងល់មិនថាអញ្ចឹង? ប្រជាជនជាច្រើននៅតែមិនដឹងឬមិនចង់ដឹងលឺថាក្មេងទាំងអស់មាននៅទីនោះ ។ សូមនឹកស្មានអំពីរបៀបប្រទេសមួយដែលមានប្រជាជនប្រហែល ២៤៥ លាននាក់ មានការយល់ដឹង និងចាប់អារម្មណ៍ ប្រសិនបើនៅមានសល់ប្រទេស ដែលដឹងអំពីជីវិតពិតប្រាកដរបស់ពួកក្មេងៗទាំងនោះ ។

ដូច្នេះអ្វីដែលយើងត្រូវតែធ្វើជាច្រើនក្នុងដំណើរការអប់រំ គឺចាប់ផ្តើមលើកវត្ថុអាថិកំបាំងចេញពីកុមារកម្មករ ។ ហេតុដូច្នេះវត្ថុបំណងជាមូលដ្ឋាននៃមេរៀននេះ គឺបង្ហាញដល់មនុស្សវ័យក្មេងនូវរបៀបដែលប្រព័ន្ធផ្សព្វផ្សាយទទួលព័ត៌មានផ្សាយពីពលកម្មកុមារនិងធ្វើឱ្យពួកគេជឿជាក់អំពីសេចក្តីត្រូវការរបស់ពួកគេ ។

## គំនូរផ្គុំរូបភាពជាអ្វី?

គំនូររូបភាពគឺជាការផ្គុំរូបភាពតូចៗ ក្នុងនោះមានរូបថតរូបភាព ហើយជួនកាលបំណែកតូចៗនៃអត្ថបទកាត់ចេញពីអត្ថបទបោះពុម្ពផ្សេងៗ ជាឧទាហរណ៍ទស្សនាវដ្តី,កាសែត,សៀវភៅចាស់ៗ ផ្ទាំងរូបភាព និងរឿងកំប្លែងហើយយកទៅបិទលើក្រដាស់មួយផ្ទាំងធំ ដើម្បីបង្កើតរូបភាព តាមការស្រមៃឃើញថ្មីមួយ ។រូបភាពថ្មីនេះគួរតែពណ៌នាអំពីប្រធានបទអ្វីក៏ដោយ ដែលត្រូវបានជ្រើសរើសសំរាប់បង្កើតរូបភាពប្រមូលផ្តុំ។ ការប្រមូលផ្គុំរូបភាព គឺជាសកម្មភាពច្របូកច្របល់ និងកំប្លុកកំប្លែងសំរាប់បំផុសអារម្មណ៍ មនុស្សវ័យក្មេង ស្ទើរតែទាំងអស់។ ការផ្គុំរូបភាពត្រូវបញ្ចប់ទៅដោយធ្វើឱ្យពួកគេសើច។ ការផ្គុំរូបភាពឱ្យត្រូវមាន កាវ, បង់ស្អិត, ខ្មៅដៃពណ៌ , ដីសពណ៌ , ហ្វឺតសរសេរ និងសម្ភារៈគ្រប់យ៉ាងដែលពួកគេអាចបិទលើក្រដាស។

## អ្វីដែលអ្នកត្រូវការ

សម្ភារៈទាំងឡាយត្រូវមានលក្ខណៈងាយស្រួល និងជាទូទៅទាក់ទងលក្ខខណ្ឌជាច្រើន ( បរិមាណនឹងអាស្រ័យ ដោយទំហំនៃក្រុម )

✓ ទស្សនាវដ្តីចាស់ៗ , រឿងកំប្លែងខ្លីៗ , សៀវភៅព័ត៌មានស្តើងៗ,ផ្ទាំងក្រដាសសម្រាប់សរសេរ, សៀវភៅតែងលំអដោយរូបភាពចាស់ៗ (ទោះយ៉ាងណាក៏ដោយសូមកុំភ្លេចសៀវភៅដែលអាចប្រើប្រាស់បាននៅឡើយ) ។

✓ ផ្ទាំងក្រដាស់ធំៗទោះប្រើហើយឬនៅថ្មីមានពណ៌ ឬអត់ពណ៌ សូម្បីតែបំណែកកាសែតចាស់ៗក៏ត្រូវប្រើធ្វើជាផ្ទៃសម្រាប់បិទរូប ឬរបស់ផ្សេងៗ។

✓ កន្ត្រៃឬប្រដាប់ប្រដាទាំងឡាយសម្រាប់កាត់រូបភាពដូចជា បន្ទាត់ដែលមានជ្រុងត្រង់ ឬក៏ជំរៀកឈើដែលមានជ្រុងសម្រាប់ហែកក្រដាស់។

✓ ជ័រកាវដែលអ្នកអាចរកបាននិងបង់ស្អិតជាច្រើនដុំ

✓ ថ្នាំលាប, ដីសពណ៌ , ហ្វឺត និងខ្មៅដៃពណ៌។

✓ បន្ទប់មួយឬកន្លែងមានផ្ទៃក្រឡា ( កម្រាលឥដ្ឋ គឺល្អដូចកន្លែងផ្សេងទៀតដែរ) ។បន្ទប់ត្រូវតែមានខ្យល់ចេញចូលប្រសិនបើអាចធ្វើទៅបាន ជាពិសេសប្រសិនបើអ្នកកំពុងប្រើជ័រកាវ អ្នកត្រូវការពារជាតិពុលដែលភាយចេញមក ។

✓ ជញ្ជាំងទំនេរសំរាប់ព្យួរឬបិទផ្ទាំងផ្គុំរូបភាព ដែលបានធ្វើរួចហើយ ។








## ការរៀបចំ

ក្នុងការរៀបចំដំណើរការសំរាប់សកម្មភាពនេះ អ្នកគួរតែអនុវត្តតាមចំនុចជាលំដាប់លំដោយដូចខាងក្រោម :

- ពិនិត្យអោយច្បាស់ថា អ្នកមានសម្ភារៈគ្រប់គ្រាន់ហើយឬនៅ ជាពិសេសបំណែកទស្សនាវដ្ដីនិងកាសែត ពិតមែនហើយរបស់ទាំងអស់នេះអាស្រ័យទៅលើកន្លែងជាក់លាក់របស់អ្នកនិងធនធានមានតំលៃជាច្រើន ។ ដូច្នោះគ្រូមិនត្រូវរួញរាឬរង់ចាំពេលក្រោយទេ ។ សម្ភារៈផ្សេងៗត្រូវឱ្យមានគ្រប់គ្រាន់ល្មមសម្ភារៈប្រើប្រាស់ ។
- ចងក្រងក្រុមសិស្សប្រមូល និងកសាងសម្ភារៈ ។ ជំរុញលើកទឹកចិត្តពួកគេឱ្យយកអ្វីដែលគេអាចយកមកពីផ្ទះរបស់ពួកគេឬក៏បរិស្ថានណាមួយដែលគេរស់នៅក៏បាន ។
- សមាជិកក្រុមប្រហែលជាត្រូវធ្វើដំណើរទៅកន្លែងចាក់សំរាម កន្លែងកែច្នៃក្រដាស់ឡើងវិញកន្លែងភ្នាក់ងារសារព័ត៌មាន ឬកន្លែងលក់រាយនូវរបស់ផ្សេងៗឬរោងបោះពុម្ព ដើម្បីប្រមូលកាសែត និងទស្សនាវដ្ដីចាស់ៗ ។
- ដោយសារមានការចូលរួមរបស់ក្រុមយ៉ាងច្រើន សិស្សនឹងមានការអភិវឌ្ឍន៍ ស្មារតីម្ចាស់ការមានភាព សប្បាយរីករាយ មានចំណាប់អារម្មណ៍ហើយនឹងមានការជំរុញលើកទឹកចិត្ត ។
- ចរិកចង់ដឹង ចង់ឮរបស់ពួកគេនឹងភ្ញាក់រលឹកឡើង ដើម្បីយល់ដឹងអំពីរឿងដែលពួកគេត្រូវការរបស់ទាំងនេះសម្រាប់ការសិក្សារបស់ពួកគេ ។

## សំភារៈផ្សេងៗ



## ចំណាងជើងផ្ទាំងផ្គុំរូបភាព

- គ្រូត្រូវរកចំណងជើងប្លែកៗគ្នា ដែលសិស្សអាចប្រើជាប្រធានបទ សម្រាប់ផ្ទាំងផ្គុំរូបភាពរបស់ពួកគេ។
- សរសេរចំណងជើងទាំងអស់ដែលគ្រូបាននឹកឃើញហើយកំឡុង ពេលមេរៀនដំបូងគ្រូត្រូវអោយក្មេងគិតរកចំណងជើងនៃរូបភាពរបស់ គេដោយខ្លួនគេផ្ទាល់។
- ប្រសិនបើពួកគេនឹកមិនឃើញទេពេលនោះគ្រូជានិច្ចកាលត្រូវមាន គំនិតដំបូងផ្ទាល់ខ្លួនរបស់គាត់ សម្រាប់ពញ្ញាក់ស្មារតី ។

## ការចាប់ផ្តើម



ជាមូលដ្ឋានអ្នកត្រូវប្រាប់ក្រុមសិស្សឱ្យបង្កើតផ្ទាំងផ្គុំរូបភាព អោយបានពីរផ្ទាំង។ ផ្ទាំងដំបូងអាចជាការផ្សព្វផ្សាយខ្លីៗ ដូចជា "វិស្សមកាលក្រោមពន្លឺព្រះអាទិត្យ" ការបង្ហាញម៉ូដ, ប្រទេសខ្ញុំ , គ្រួសារខ្ញុំ, មិត្តភ័ក្តិខ្ញុំ។ ផ្ទាំងទីពីរអាចផ្សព្វផ្សាយអំពីពលកម្មកុមារ។

នៅដំណាក់កាលដំបូងនៃមេរៀន មុនការចាប់ផ្តើមកិច្ចការអ្វីមួយ គ្រូត្រូវពន្យល់ក្រុមសិស្សអំពីអ្វីដែលសកម្មភាពនេះត្រូវការប្រើប្រាស់ គ្រូមិនត្រូវប្រាប់ដល់ពួកគេ នូវប្រធានបទរបស់គំនូរទីពីរ នៅដំណាក់កាលនេះទេ។ គ្រូគ្រាន់តែប្រាប់ពួកគេថា នឹងមានគំនូរពីរផ្ទាំងទៀតដែលមានន័យតែប៉ុណ្ណោះ ប៉ុន្តែមិនមែនជាផ្ទាំងគំនូរទីពីរនោះទេ។ កិច្ចការនេះ គឺជាលំហាត់ធម្មតា និងកំប្លុកកំប្លែងមួយ ហើយពួកគេត្រូវតែទទួលយកកិច្ចការនេះ។ ត្រូវដឹងអោយច្បាស់ថា ពួកគេទាំងអស់បានចូលរួមធ្វើកិច្ចការ ហើយថាមពលរបស់ក្រុមចាប់ផ្តើមកើតមានឡើង។

### ការរៀបចំក្រុម



ប្រសិនបើក្រុមសិស្សមានគ្នាច្រើន គ្រូត្រូវបែងចែកពួកគេជាក្រុមតូចៗសមស្របតាមទំហំកន្លែង និងសម្ភារៈ ដែលគ្រូអាចបែងចែកអោយពួកគេ។ ប្រសិនបើក្រុមដំបូងតូច (មាន៥នាក់ឬក៏តិចជាង៥នាក់) ពួកគេអាចធ្វើការពីរនាក់ ឬក៏ម្នាក់ឯង។ គ្រូត្រូវព្យាយាមមិនឱ្យមានសិស្សលើសពី៥នាក់ក្នុងមួយក្រុម។ ត្រូវដឹងឱ្យច្បាស់ថា គ្មានសិស្សណាមួយស្ថិតនៅស្ងៀមស្ងាត់ក្រោយខ្នងអ្នកដទៃទៀតដែលធ្វើកិច្ចការនោះទេ។ ជាឧទាហរណ៍សិស្សម្នាក់ ឬពីរនាក់អាច ស្វែងរកតាមរយៈទស្សនាវដ្ដីសម្រាប់រូបភាពពិតប្រាកដ ខណៈពេលសិស្សដទៃអាចធ្វើការកាត់ ហើយអ្នកដទៃផ្សេងទៀតបិទរូបភាពលើផ្ទាំងក្រដាស់។ អ្នកគ្រាន់តែពិនិត្យឱ្យច្បាស់ថាមានសហប្រតិបត្តិការជាច្រើន(ហើយសកម្មភាព គឺសប្បាយរីករាយទាំងអស់គ្នា)។

## សកម្មភាព១ : ផ្ទាំងផ្គុំរូបភាពធម្មតា



*បង្រៀនមួយពេល (ឬម្ដងកន្លះពេលជាការប្រសើរជាង)*

គ្រូហៅក្រុមសិស្សឱ្យបង្កើតផ្ទាំងផ្គុំរូបភាពជាមួយសម្ភារៈដែលអាចប្រើប្រាស់បាន (ពន្យល់ពីអ្វីដែលមានន័យតាមរយៈ ផ្ទាំងផ្គុំរូបភាពចំពោះសិស្សទាំងឡាយដែលមិនទាន់យល់ច្បាស់) បកស្រាយខ្លឹមសារនៃប្រធានបទ ដែលជ្រើសរើសលើកទឹកចិត្តពួកគេឱ្យប្តូរគ្នានូវចំណងជើងរូបភាព សរសេរចំណងជើងខ្លះលើក្តារខៀនឬលើក្រដាសមួយផ្ទាំង រួចឱ្យពួកគេជ្រើសរើសយកចំណងជើងមួយណាដែលពួកគេយល់ស្រប។

ប្រមូលសម្ភារៈទាំងនោះទៅដាក់ក្នុងកន្លែងមួយ បន្ទាប់មកអនុញ្ញាតិឱ្យពួកគេរយៈពេល២០នាទី ដើម្បីយកសម្ភារៈទាំងនោះ បង្កើតផ្ទាំងផ្គុំរូបភាពរបស់ពួកគេ។ អ្នកកុំផ្តល់ពេលវេលាឱ្យពួកគេយូរពេក បើមិនដូច្នេះទេពួកគេប្តូរទៅជាបាត់បង់ចំណាប់អារម្មណ៍ និងបាត់ការយកចិត្តទុកដាក់។ ដើរពិនិត្យក្រុមទាំងអស់ ខណៈដែលពួកគេកំពុងធ្វើការ។ និយាយទៅកាន់ពួកគេអំពីអ្វីដែលពួកគេកំពុងបង្កើត។

ផ្តល់ពាក្យប្រលយ ឬក៏ដំបូន្មាន។

លើកទឹកចិត្ត និងជំរុញឱ្យមានការផ្លាស់ប្តូរយោបល់រវាងក្រុមទាំងឡាយក៏ប៉ុន្តែរក្សាអ្វីៗឱ្យមានអារម្មណ៍ល្អ និងមិនមធ្យ័តពេកទេ។ គឺនៅមានពេលវេលាច្រើនសម្រាប់ការពិភាក្សាយ៉ាងល្អិតល្អន់ ជាច្រើននៅក្នុងមេរៀនផ្សេងទៀត។

នៅពេលដល់ម៉ោងកំណត់ គ្រូឱ្យក្រុមសិស្សលើកផ្ទាំងផ្ទុំរូបភាពរបស់ពួកគេសម្រាប់ឱ្យក្រុមដទៃទៀតមើល ( ឬក៏ឱ្យសិស្សបិទផ្ទាំងផ្ទុំរូបភាពលើក្តារខៀន, តាមជញ្ជាំងដែលជាកន្លែងដែលសិស្សដទៃៗទៀតអាចមើលឃើញ) ហើយហៅសមាជិកក្រុមឬក៏អ្នកតំណាងក្រុមឱ្យមកពន្យល់ពីអ្វីដែលរូបភាពរបស់ពួកគេចង់បង្ហាញឱ្យឃើញ។ ស្នើក្រុមដទៃទៀតឱ្យជួយផ្តល់ យោបល់ កែលំអ ឬក៏ជាសំណួរ។

ដើម្បីធ្វើអ្វីមួយឱ្យមានតំលៃគ្រូអាចបញ្ចូលចំណុចសំខាន់ណាមួយទៅក្នុងការប្រកួតប្រជែង ឧទាហរណ៍ ដូចជា :

- គ្រូប្រាប់ក្រុមសិស្សទាំងអស់ឱ្យរក្សាចំណងជើងនៃផ្ទាំងផ្ទុំរូបភាពរបស់ពួកគេជាសំងាត់ ហើយបន្ទាប់មកឱ្យក្រុមដទៃទាយចំណងជើង។
- ឱ្យក្រុមដទៃបោះឆ្នោតផ្ទាំងផ្ទុំរូបភាពដែលគេចូលចិត្ត ហើយជ្រើសរើសអ្នកឈ្នះ។
- អោយក្រុមមួយទៀតនៃពួកក្មេង ( ថ្នាក់ដទៃទៀត បើសិនអ្នកនៅក្នុងសាលាតែមួយ) មកទស្សនាផ្ទាំងផ្ទុំរូបភាព ហើយនឹងដើរតួជាអ្នកវិនិច្ឆ័យ។
- ទោះយ៉ាងណាក៏ដោយគ្រូមិនត្រូវបង្កើតការប្រកួតប្រជែងច្រើនពេកទេ។ ទិសដៅ គឺមិនមែនដាក់នៅដាច់ពីអ្នកទាំងនោះ អ្នកដែលមានទំនោរខាងសិល្បៈតិចជាងអ្នកដទៃដែលនៅឆ្ងាយឡើយ។ ក៏ប៉ុន្តែត្រូវបង្កើតបរិយាកាសសប្បាយរីករាយ និងមានអារម្មណ៍ជាមិត្ត ក្នុងចំណោមក្រុម។ ប្រសិនបើអ្នកមានអារម្មណ៍ថា ការជំរុញការប្រកួតប្រជែងលើកទឹកចិត្តនឹងនាំឱ្យមានភាពតានតឹង

ហើយ ប្រហែលជានឹងធ្វើឱ្យអន្តរាយនូវភាពស្វាហាប់នៃក្រុមសិស្សនេះ
គ្រូត្រូវអនុវត្តតាមគំនិតរបស់ខ្លួន ហើយកុំអនុវត្តតាមការប្រកួតប្រជែង ។

## សកម្មភាព២ : ផ្ទាំងផ្គុំរូបភាពអំពីពលកម្មកុមារ

*បង្រៀនមួយពេល (ឬមួយកន្លះពេលជាការប្រសើរ)*



ខណៈពេលដែលលំហាត់ផ្គុំរូបភាពទី១ ត្រូវបានបញ្ចប់គ្រូត្រូវប្រាប់ដល់ពួកគេនូវប្រធានបទសម្រាប់ផ្គុំរូបភាពទី ពីររបស់ពួកគេ គឺចក្ខុវិស័យរបស់ពួកគេស្តីអំពីពលកម្មកុមារ ។ អ្នកមិនគួរបន្ថែមអ្វីទៀតដោយខ្លួនឯងនៅដំណាក់កាល នោះទេ ។ អ្នកប្រហែលជាបានបង្រៀនតាមសៀវភៅ ពតិមានជាមូលដ្ឋាន រួចរាល់ហើយមុននឹងប្រតិបត្តិមេរៀនមួយនេះ ។ ដូច្នេះក្រុមសិស្សនឹង បានគោលគំនិតខ្លះ អំពីអ្វីដែលហៅថា ពលកម្មកុមារ ។ អនុញ្ញាតិអោយពួកគេស្រាវជ្រាវអោយ បានហ្មត់ចត់បន្ថែមទៀត ដើម្បីជំរុញការស្រមៃផ្ទាល់ខ្លួន របស់ពួកគេ ។ ដំណាក់កាលនេះ គឺមិនមែននិយាយអំពីចក្ខុវិស័យនិងការយល់ ដឹង របស់អ្នក អំពីរឿងរ៉ាវពលកម្មកុមារទេ ។ ក៏ប៉ុន្តែនេះជាពេលវេលាដែលអ្នកជំរុញលើកទឹកចិត្តពួកគេ ។

ត្រូវប្រាប់ពួកគេថា ពួកគេអាចបង្កើតផ្ទាំងផ្គុំរូបភាពទ្រង់ទ្រាយណាមួយក៏បានឱ្យតែផ្ទាំងផ្គុំរូបភាពនោះ ពណ៌នាពីពលកម្មកុមារ ។ ពួកគេច្បាស់ជាបង្កើតផ្ទាំងផ្គុំរូបភាពតាមវិធីដូចគ្នាក្នុងដំណាក់កាលដំបូង ដូចជាការកាត់រូបភាពចេញពីទស្សនាវដ្តីចាស់ៗហើយនឹងកាសែតដែលអាចប្រើប្រាស់បាន និងការបិទរូបភាពទាំងនោះនៅលើផ្ទៃរាបផ្សេងទៀត ។ អនុញ្ញាតិអោយពួកគេនូវម៉ោងដូចគ្នា និងធ្វើការក្រោមល័ក្ខខណ្ឌដូចគ្នា (ប្រហែលជាពួកគេត្រូវការពេលច្រើន បើពេលវេលាតិច ពួកគេនឹងមិនអាចអនុវត្តកិច្ចការអោយបានល្អទូលំទូលាយបានឡើយ ។ ត្រូវពិនិត្យតាមមើលឱ្យច្បាស់នូវទំរង់ការផ្សេង ដែលអាចដំណើរការ ។

រឿងរ៉ាវពីរ នៃកិច្ចការមួយនឹងកើតមានឡើង។ ទីមួយក្រុមសិស្សប្រហែលជាយកសម្ភារៈខ្លះៗក្នុងចំណោមសម្ភារៈទាំងអស់ដែលមានស្រាប់មកប្រើប្រាស់។ ពួកគេមិនអាចនឹករកអ្វីដែលគេមានអារម្មណ៍ថា គេអាចប្រើដើម្បីបង្កើតផ្ទាំងផ្ដុំរូបភាពស្ដីពីពលកម្មកុមារបានឡើយ។ បញ្ហានេះមិនជាអ្វីទេក្នុងករណីភាគច្រើន បញ្ហានេះយើងត្រូវគិតថានឹងកើតមានពិតប្រាកដ។ ពួកគេនឹងបង្កើតអ្វីមួយ ប៉ុន្តែមិនលំអិតដូចកិច្ចការមុនទេ។

ឆាកដែលអាចកើតឡើងទីពីរ គឺថាក្រុមខ្លះប្រហែលជាមានភាពប៉ិនប្រសព្វ ការឆាប់យល់ដឹង និងភាពជាសិល្បករដែលឆាប់ទទួល អារម្មណ៍ ប្រសិនបើរឿងរ៉ាវនេះកើតមានឡើងពេលនេះ អ្នកនឹងមានសំណាងយ៉ាងល្អ ខណៈដែលលទ្ធផលនៃផ្ទាំងផ្ដុំគំនូរទាំងអស់នោះមានការស៊ីជំរៅអំពីសិល្បៈ

ដូចជាមួយផ្ទាំងផ្ដុំរូបភាពពីមុនអញ្ជើងគ្រូឱ្យក្រុមសិស្សលើករូបភាពពួកគេឡើងឬបើមិនដូច្នេះទេ ឱ្យពួកគេបង្ហាញរូបភាពពួកគេ និងពន្យល់ពីគំនិតដែលនៅពីក្រោយរូបភាពរបស់ពួកគេទៅកាន់សិស្សដទៃទៀត។ លើកទឹកចិត្តឱ្យក្រុមទាំងមូលមានគំនិតកែលំអ ហើយជាការល្អត្រូវមានការប្រកួតប្រជែងសំរាប់ជ្រើសរើសកិច្ចការល្អបំផុត។

## អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ



- មិនត្រូវអនុញ្ញាតិឱ្យក្រុមខ្លះទិតៀន ឬចំអកក្រុមដទៃទៀត ទេ។ ត្រូវធ្វើឱ្យមានការផ្ដោតទៅលើអ្វី ដែលជាវិជ្ជាមាននៅក្នុងរឿងនីមួយៗ។
- ប្រសិនបើអាចត្រួតពិនិត្យបានត្រូវអនុញ្ញាតិឱ្យមានការ ជជែកលេងសើច ការនិយាយទាក់ទងគ្នា ភាពឆាឆៅគ្នា ការកំប្លុកកំប្លែងលេងសើច និយាយកំប្លែងដោយមានការប្រកួតប្រជែង។
- មិនត្រូវផ្ដល់ឱ្យក្រុមនីមួយៗនូវរយៈពេលខុសគ្នា ដើម្បីធ្វើឱ្យបានសំរេចនូវផ្ទាំងផ្ដុំរូបភាពអ្នកមិនត្រូវពិនិត្យកិច្ចការសិល្បៈទាំងអស់ទេ។ អ្នកត្រូវព្យាយាមធ្វើកំណត់សំគាល់ជាបន្តបន្ទាប់។ ទោះ



យ៉ាងណាក៏ដោយប្រសិនបើការងារសិល្បៈមានដំណើរការល្អ អ្នកត្រូវផ្តល់ពេលវេលាកំណត់មួយ ដើម្បីធ្វើឱ្យការងារបានសំរេចអ្នកត្រូវដើរមើលក្នុងចំណោមពួកគេមានការលើកទឹកចិត្តពួកគេឱ្យបញ្ចប់កិច្ចការទាន់ពេលដែលត្រូវបានអនុញ្ញាតិ ។

- ត្រូវផ្តល់ពេលវេលាដើម្បីព្យួររូបភាពនីមួយៗ ហើយលើកទឹកចិត្ត និងកោតសរសើរគ្នាទៅវិញទៅមក ពិសេសនាំអោយមានការពិភាក្សា ។

## ការពិភាក្សាបញ្ចប់

### "បង្រៀនមួយពេល"

ការពិភាក្សាចុងក្រោយជាមួយក្រុមសិស្ស គួរតែបញ្ចូលបញ្ហាពលកម្មកុមារ ដែលជារឿងមួយពោរពេញដោយការរំលោភសិទ្ធមនុស្សដ៏អាក្រក់បំផុតចំពោះពួកយើង ហើយការរំលោភនេះបន្តរាលដាលពាសពេញពិភពលោក ។ ដូច្នេះ ប្រព័ន្ធផ្សព្វផ្សាយតូចមួយក៏អាច( ផ្តល់នូវប្រយោជន៍) គឺផ្សាយបាតុភូតអាក្រក់នេះ ហើយវាធ្វើឱ្យមានការស្អប់ការរំលោភនេះកាន់តែខ្លាំងឡើងក្នុងពិភពលោក ក្រុមសិស្សឥឡូវយល់បញ្ហានេះកាន់តែប្រសើរ ។ ពីព្រោះពួកគេបានឃើញនូវភាពងាយស្រួលក្នុងការបង្កើតផ្ទាំងផ្ទាំងរូបភាពស្តីពីទិដ្ឋភាពនៃជីវិត ។ ជាពិសេស គឺរឿងវិជ្ជមាន រឿងល្អហើយនិងការលំបាក ក្នុងការបង្កើតរឿងមួយស្តីពីទិដ្ឋភាពអាក្រក់នៃជីវិត ។

ទោះបីក្រុមខ្លះបានផ្ទាំងផ្ទាំងរូបភាពស្តីពីពលកម្មកុមារ ហើយផ្ទាំងផ្ទាំងរូប-ភាពនោះល្អបំផុត ក៏ដោយគឺពួកគេនឹងនៅតែកត់សំគាល់ថា វាមានការលំបាកក្នុងការបង្កើតរូបភាពខ្លាំងជាងការបង្កើតអោយមាន " អារម្មណ៍ល្អ" ។

ជំរុញអោយមានការពិភាក្សាទូទៅមួយក្នុងចំណោមក្រុមស្តីពីការមើលមិនឃើញបញ្ហាពលកម្មកុមារ ។ សួរពួកគេពីអ្វីដែលពួកគេមានអារម្មណ៍អំពីការមិនយកចិត្តទុកដាក់ចំពោះពលកម្មកុមារ ។

- តើពួកគេគិតថា រឿងនោះគឺជាការខុសឆ្គងឬទេ ?
- តើប្រព័ន្ធផ្សព្វផ្សាយគួរតែយកចិត្តទុកដាក់បន្ថែមទៀតចំពោះរឿងនេះ?
- តើវាគឺជារឿងសំខាន់គួរអោយផ្សាយឬទេ?
- តើនរណាជាអ្នកកំណត់ឱ្យចេញផ្សាយឬក៏មិនចេញផ្សាយ ?
- តើកត្តាអ្វីខ្លះដែលគួរបញ្ចូលក្នុងដំណើររឿង ពេលដែលបានបោះពុម្ព ឬផ្សព្វផ្សាយតាមទស្សនាវដ្ដីសម្រាប់កុមារពលកម្ម ?
- តើក្រុមណាខ្លះនឹងទិញដោយចាំបាច់ឬក៏មើលត្រួសៗ ទស្សនាវដ្ដីមួយដែលមានរូបភាព និងអត្ថបទស្ដីពីពលកម្មកុមារ ? ដោយសេចក្ដីស្មោះត្រង់នោះពួកគេមួយចំនួនខ្លះប្រហែលជានឹងមិនអាន ឬទិញទេ។
- តើរឿងនេះប្រាប់ពួកគេឱ្យដឹងអ្វីខ្លះអំពីសង្គម និងគោលការណ៍ព្រមទាំងតំលៃរបស់វានៅពេលសព្វថ្ងៃនេះ ?

ការពិភាក្សាខ្លះពិតជាពិបាក ជាពិសេសសម្រាប់មនុស្សពេញវ័យ ទាំង ឡាយដែលមានបញ្ហាជាច្រើន (តាំងពីយូរមកហើយ) និងបញ្ហាថ្មីៗរបស់ ពួកគេ។ ការពិភាក្សាអាចបង្កផលពិបាកដល់ពួកគេ និងធ្វើឱ្យពួកគេក្លាយជាក្រុមស្ទាក់ស្ទើរក្នុងសកម្មភាពខ្លះបន្តទៀត។ ដូច្នេះគ្រូត្រូវប្រុងប្រយ័ត្នក្នុងការចាត់ចែងការពិភាក្សា។ ត្រូវដឹងអោយច្បាស់ថា ការចូលរួមស្មើរតែទាំងអស់បានមកពីពួកគេពីការណែនាំ និងពីការលើកទឹកចិត្តរបស់អ្នក។ ត្រូវយកមក បញ្ចូលប្រធានបទដទៃទៀត ផ្នែកខ្លះនៃសិទ្ធិមនុស្សដែលប្រហែលជាត្រូវបានបកស្រាយ និងផ្សព្វផ្សាយតិចឬច្រើនក្នុងប្រព័ន្ធផ្សព្វផ្សាយជាឧទាហរណ៍ ដូចជាប៉ះទង្គិចសង្គមស៊ីវិល និងជនភៀសខ្លួន។ ហេតុអ្វីបានជាមានរឿងអញ្ចឹង? តើអ្វីដែលធ្វើឱ្យពួកគេមានតម្លៃសក្ដិសមនឹងការផ្សព្វផ្សាយ។

គ្រោះថ្នាក់ចំបងដែលត្រូវប្រុងប្រយ័ត្ន គឺមិនមែនបញ្ហាបង្កើត អារម្មណ៍អស់សង្ឃឹមទេ ប្រសិនបើយុវជនមានអារម្មណ៍ថា ប្រធានបទនេះធំធេងពេកស្មុគស្មាញ និងហួសពីការទទួលបានចំពោះពួកគេ នោះពួកគេនឹងបាត់បង់ជំនឿចិត្តយ៉ាងរហ័ស។ គ្រូត្រូវបង្ហាញឱ្យឃើញច្បាស់នូវភាពល្អ និងអ្វីដែល វិជ្ជមាន។

- ឥឡូវពួកគេមានការយកចិត្តទុកដាក់ចំពោះស្ថានភាព ។
- ពួកគេប្រហែលជាចង់ធ្វើអ្វីមួយស្តែងចេញពីស្ថានភាព ។
- ពួកគេអាចរៀបរាប់ប្រាប់ដល់អ្នកដទៃទៀត ។
- ពួកគេគឺជាអ្នកប្រើប្រាស់ហេតុដូច្នេះ ពួកគេត្រូវបំពេញតួនាទីមួយ ។



## ការវាយតម្លៃ និងសកម្មភាពបន្ត



ចំនុចសំខាន់ៗ ដែលគួរអោយកត់សំគាល់របស់សៀវភៅនេះ គឺលទ្ធផលជាក់លាក់ដែលអាចកើតមានឡើងឬអត់ដូចជា :

- ផ្ទាំងផ្តុំរូបភាពទាំងអស់ស្តីពីប្រធានបទផ្សេងៗ ។ ក្រុមនីមួយៗ គួរតែបង្កើតប្រភេទផ្សេងៗនៃរូបភាព ឬគំនូរផ្តុំគ្នាមួយ ។ ប្រសិនបើពួកគេមិនបានបង្កើតទេ អ្នកគប្បីរកឱកាសអនុវត្តសៀវភៅនេះសារជាថ្មីនៅពេលដែលក្រុមយុវជនយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះប្រធានបទទាំងនោះ ។ អ្នកអាចធ្វើការជាក្រុម ដែលមានការលំបាកដោយឈរលើគោលការណ៍ស្វែងរកចំលើយល្អៗ ។ ត្រូវធ្វើការជាមួយក្រុមជាបន្តទៅទៀត ព្រោះមានសៀវភៅផ្សេងទៀតដែលអាចពញ្ញាក់អារម្មណ៍លើកកំពស់ការយកចិត្តទុកដាក់ និងការសន្យាចូលរួមរបស់ពួកគេផងដែរ ។
- ផ្ទាំងផ្តុំរូបភាពទាំងឡាយស្តីពីពលកម្មកុមារនេះគឺជាសញ្ញាជោគជ័យពិតប្រាកដ ទោះបីរូបភាពទាំងនេះមិនត្រូវបង្កើតទៅតាមអ្វី

ដែលពួកវាត្រូវបង្កើតក៏ដោយក្រុមសិស្សត្រូវស្វែងរកឱ្យឃើញការ លំបាក ប្រសិនបើពួកគេមិនអាចបង្កើតផ្ទាំងផ្ទាំងរូបភាព។ ទោះយ៉ាងណាក៏ដោយ រូបភាពផ្ទាំងខ្លះ ដែលពួកគេបានបង្កើត គឺមានលក្ខណៈប្រឌិតខ្លាំងណាស់ ហើយអ្នកគួរតែធ្វើសកម្មភាព ឬសំដែងទៅតាមរូបភាពនេះ។ ពួកគេអាចជាកំលាំងស្នូលដ៏សំខាន់នៃយុទ្ធនាការបង្កើនការយល់ដឹងនៅក្នុងសហគមន៍ និងបរិស្ថាននៃការរស់នៅ ហើយអ្នកគួរតែប្រើប្រាស់ពួកគេឱ្យបានទូលំទូលាយជាមួយនឹងប្រព័ន្ធផ្សាយថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ (មើលខាងក្រោម)។ នេះគឺជាចំណុចចំបងមួយនៃជ័យជំនះគួរឱ្យកត់សំគាល់ ហើយវាធ្វើឱ្យទិដ្ឋភាពនៃសៀវភៅរបស់អ្នកមាននិរន្តរភាព។ សៀវភៅមានលក្ខណៈសាមញ្ញងាយស្រួលយល់ប៉ុន្តែជាមធ្យោបាយដែលមានប្រសិទ្ធិភាពសម្រាប់បង្ហាញអោយឃើញការលំបាកដែលមានទីតាំងពីដើមមករបស់កុមារពលកម្មដែលគេមើលមិនឃើញ ហើយមនុស្សទាំងឡាយមើលហួស ឬបំភ្លេចវាចោលដោយសំអាងហេតុផលផ្សេងៗ។ ការអប់រំអំពីពលកម្មកុមារសម្រាប់យុវជនត្រូវបង្ហាញ និងទាញអារម្មណ៍ឱ្យផ្តោតលើការយល់ដឹងក្នុងចំណោមពួកគេ។ពួកគេគួរតែដកស្រង់មេរៀនសំខាន់ៗចេញពីសៀវភៅនេះ ពួកគេត្រូវចាប់ផ្តើមយល់ដឹងនូវតំរូវការដើម្បីច្បាមយកសម្រែកនៃការមិនអើពើ (ភាគកំផែល)របស់សង្គម និងស្វែងរកការពិតអំពីអ្វីដែលបានកើតមាននៅក្នុងពិភពលោក។

រឿងនេះមានន័យថា មិនចាំបាច់ជឿអ្វីៗទាំងអស់ដែលប្រព័ន្ធផ្សព្វផ្សាយជ្រើសរើសមកបំរើអតិថិជនទាំងអស់ឬក៏យ៉ាងហោចណាស់គោលដៅជាច្រើនក្នុងព័ត៌មាន គឺគំរាមកំហែង។ ប្រសិនបើអ្នកអាចធ្វើផ្ទាំងផ្ទាំងរូបភាពអ្នកត្រូវទុកវាក្នុងបន្ទប់ដែលអ្នកកំពុងប្រើប្រាស់សម្រាប់ធ្វើគំរោង ឬ ក៏ទុកក្នុងបន្ទប់ខាងមុខទ្វារដែលអ្នកដទៃអាចមើលឃើញ។ការងារផ្សេងៗគ្នាស្តីពីពលកម្មកុមារដែលត្រូវបានបង្កើតដោយក្រុមសិស្សជាច្រើន គឺជាវិធីដ៏ល្អឥតខ្ចោះមួយផងដែរ សម្រាប់ការធ្វើ និងបោះពុម្ពផ្សព្វ-ផ្សាយគំរោងក្នុងចំណោមអ្នកស្តាប់ដោយផ្ទាល់តែម្តងលើកទឹកចិត្តយុវជន

វ័យក្មេងដទៃទៀតឱ្យក្រឡេកមើលគំរូ និងបញ្ចុះបញ្ចូលអ្នកធ្វើរបាយការណ៍ទាំងឡាយឱ្យមកថតរូបភាពទាំងនោះ សម្រាប់ព័ត៌មានជាតិ និងមូលដ្ឋាន។

រូបភាពទាំងអស់នឹងបង្ហាញនូវសេចក្ដីថ្លែងការណ៍ដ៏មានអានុភាពអំពីពលកម្មកុមារ ហើយវាមានសារៈសំខាន់រឿងដែលអ្នកអញ្ជើញសមាគមន៍ឱ្យចូលរួមវាយតំលៃ និងកោតសរសើរការងាររបស់យុវជនត្រូវរៀបចំពិព័រណ៍សាធារណៈមួយស្ដីពីការងារទាំងឡាយ ហើយអញ្ជើញសមាជិកសហគមន៍ទាំងអស់គ្រួសារសិស្សអ្នកនយោបាយតាមមូលដ្ឋានអ្នកតំណាងសហជីពពាណិជ្ជកម្ម និងអង្គការក្រៅរដ្ឋាភិបាល និងនិយោជិកមូលដ្ឋានដើម្បីទស្សនា។ លក់ឡាយឡុងស្នាដៃទាំងនេះ ដើម្បីរកថវិកាសម្រាប់សកម្មភាពទាំងឡាយក្នុងគោលបំណងបញ្ឈប់ពលកម្មកុមារឬសម្រាប់ទិញសម្ភារផ្សេងៗ ដើម្បីធ្វើអំណោយដល់សាលានានាសម្រាប់កម្មករកុមារដែលត្រូវបានជួយសង្គ្រោះ។ បញ្ហានេះប្រហែលជាលើកដំបូង ហើយដែលសហគមន៍ឮពីគំរោង និងប្រធានបទនេះ។ ដូច្នេះត្រូវចាប់ផ្ដើមរៀបចំការងារ នៅតាមមូលដ្ឋានសម្រាប់ការផ្សព្វផ្សាយនៅពេលអនាគត និងការអញ្ជើញសហគមន៍ឱ្យចូលរួម។ ហេតុដូចនេះក្រុមសិស្ស ដែលអ្នកកំពុងធ្វើការជាមួយត្រូវចាប់ផ្ដើមរកឱ្យឃើញគោលបំណងធំទូលាយមួយសម្រាប់កិច្ចការរបស់ពួកគេ។

ខណៈដែលអ្នកបានបញ្ចប់សៀវភៅនេះដោយពេញចិត្តរួចហើយ ចូរអ្នកបន្តទៅសៀវភៅថ្មីមួយទៀត យើងផ្ដល់ជាអនុសាសន៍ថា សៀវភៅបន្ទាប់ដែលអ្នកត្រូវអានពិនិត្យដោះស្រាយគឺជាសៀវភៅមួយដែលចំណងជើងថា"**រូបភាព**"

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

១_លោក ភុង ហនស៊ីន ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

២_លោក តូច ធឿន អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៣_លោក តូច គូលអ អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៤_លោក ចាប តឹមជុន អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៥_លោក ណុប ទឹម ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

## គណៈកម្មការរៀបរៀង និងចងក្រង

១_លោក ភុង ហនស៊ីន ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

២_លោក តូច ធឿន អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៣_លោក តូច គូលអ អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៤_លោក ចាប តឹមជុន អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៥_លោក ណុប ទឹម ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៦_លោក ឡង់ សុផាត មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

## គណៈកម្មការបកប្រែ

១_លោកស្រី កង សុថាវី ប្រធានការិយាល័យក្រោយអក្ខរកម្ម

២_លោកស្រី តុប ប៊ុនថា ប្រធានការិយាល័យអក្ខរកម្ម

៣_លោក ព្រៀម ភីណារ៉េត អនុប្រធានការិយាល័យរដ្ឋបាល

៤_លោក តេះ ដារី អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ

៥_លោក ជិន និវត្តន៍ មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៦_លោកស្រី ទី វត្តី មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៧_លោក ភូ យន់ មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៨_លោកស្រី ស្រ៊ុន ម៉ាទី មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៩_កញ្ញា អ៊ុក ធារី មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

១០_លោក គ្រួច លក្ខិណា មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

១១_លោកស្រី លី ខេង មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

## គណៈកម្មការផ្ទៀងផ្ទាត់

១_លោក សំ ចាន់ទិត អនុប្រធានការិយាល័យអក្ខរកម្ម

២_លោក រង់ សូវង្ស មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៣_លោក ឈុំ ច័ន្ទមុនីរ៉េត មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៤_លោកស្រី ជា សុផល មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៥_លោក កែវ តង់ មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៦_កញ្ញា ម៉ៅ ផល្លី មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

៧_លោកស្រី ស្រ៊ុន ម៉ាទី មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

១_លោក ឈិន វិត ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

២_លោក ពេជ្រ និពន្ធ មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

៣_លោកស្រី ឈុំ សោភ័ណ មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

៤_លោកស្រី សួច ផាន់ណា មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

៥_លោកស្រី ទី រ៉ាដា មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

៦_កញ្ញា សន សុម៉ាលី មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

# បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


## សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាឆីរ ប៉ូល យុសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់(TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗនិងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : nfe@camnet.com.kh



ISBN-9789995088217